# ការសម្ភាសន៍របស់បងប្រុស ហេង ណៃម

កះ អ្នកសម្ភាសន៍ឈ្មោះ ម៉េត អេងសួរ ខះ អ្នកត្រូវបានសម្ភាសន៍ ហេង ណៃម

## <u>សង្ខេបរបស់បងប្រុស ហេង ណៃម</u>

បងស្រី ហេង ណៃម មានអាយុ ៥៧ឆ្នាំកើតនៅ ភូមិឈើទាលស្រុតលើ ឃុំរំចេក ស្រុកកំពុងសៀម ខេត្តកំពុងចាម ។ ស្វាមីរបស់បងមានឈ្មោះ ច្រិច ជា ពួកគាត់ទាំង២ មានកូន ៦នាក់ទី១ឈ្មោះ ជា ស្រីនាថ ទី២ ជា ចិន ទី៣ ជា ម៉េងជាវ ទី៤ ជា ស្រីណា ទី៥ ជា ស្រីណុច ទី៦ ជា សុជាតិ ។
បងស្រីមានឪពុកឈ្មោះ ឡេង ហេង នឹងអ្នកម្តាយឈ្មោះ វន សាត ។
បងស្រីគាត់មានបងប្អូនប្រុសស្រី ៦នាក់ ។

កះ ជាដំបូងញ៉ុមសុំថ្លែងអំណរគុណដល់ចៃ
ដែលផ្តល់ឧកាសអោយញ៉ុមធ្វើការសម្ភាសន៍ចៃនៅថ្ងៃហ្នឹងហើយចំពោះការសម្ភាសន៍នេះគឺធ្វើឡើងដោយសកលវិទ្យាល័យមួយនៅ សហរដ្ឋអាមេរិច ដែលមានឈ្មោះថា BYU
សកលវិទ្យាល័យមានគំរោងបង្កើតគំរោងនេះឡើងដើម្បីអ៊ែរ ...
ចងក្រងប្រវត្តិរបស់ប្រជាជនខ្មែរទុកដើម្បីអោយកូនចៅជំនាន់ក្រោយរបស់ពួកគេដឹងអំពីប្រវត្តិដូនតារបស់ខ្លួន ។ ហើអ៊ែរ ... ញ៉ុមសុំអនុញ្ញាតិបងស្រីអ៊ែរ ...
ដាក់ការសម្ភាសន៍នេះចូលទៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា
WWW.cambodianoralhistories.byu.edu បានអត់បងស្រី? Hello បងស្រី!

ខះ Hello!

កះ បានអត់ ? ញ៉ុមអាចដាក់ប្រវត្តិបានអត់ ?

ខះ បាន!

កះ អគុណច្រើនណាបង ហើយការសម្ភាសន៍របស់យើងគឺធ្វើឡើងនៅថ្ងៃទី ១៥ ខែមេសាឆ្នាំ ២០១៨ ។ ធ្វើឡើងនៅភូមិ ឈើទាលស្រុតលើ ឃុំរំចេក ស្រុកកំពុងសៀម ខេត្តកំពុងចាម ។ អ៊ែរ ... ញ៉ុមចង់សួរបងស្រីថា តើបងមានឈ្មោះអីដែលបង ?

ខះ ឈ្មោះ ហេង ណៃម ម៉ងទៅ ។

ក៖ ហ្នឹងហើ! ហ្នឹងហើឈ្មោះពេញមែនបង ?

ខ៖ ហ្នឹងហើ! ឈ្មោះពិតម៉ងអត់មាន ២ ៣ ហេ ។

ក៖ ចុះបងមានឈ្មោះហៅក្រៅអីទៀតអត់បង ?

ខ៖ អត់!

ក៖ អ័រឈ្មោះ ហេង ណែម! ហេង ណែម! អញ្ចឹងម៉ងណ៎បងណ៎ ? ចុះបងមានអាយុមាណហើបង ?

ខ៖ ៤៧ឆ្នាំ ។

ក៖ ចុះបងអ័រ ... ចាំថ្ងៃ ខែ ឆ្នាំ កំណើតរបស់បងអត់ ?

ខ៖ អត់ដឹងទេ! ដឹងតាកើតឆ្នាំ ១៩៧០ ។

ក៖ ១៩៧០! ចុះបើជាឆ្នាំខ្មែរវិញជាឆ្នាំសត្វអីទៅបង ?

ខ៖ ឆ្នាំសត្វ ជ្រូក ។

ក៖ ឆ្នាំសត្វ ជ្រូក ណ៎បង ? ចុះបងមានទីកន្លែងកំណើតនៅណាដែលបង ?

ខ៖ ភូមិឈើទាលស្រុតលើ ឃុំរំចេក ស្រុកកំពុងសៀម ខេត្តកំពុងចាម ។

ក៖ ហ្នឹងហើ! អ័រ ... ចុះបងមានបងប្អូនមាណនាក់ដែល ?

ខ៖ ៥នាក់ ។

ក៖ បងអាចរៀបរាប់ឈ្មោះរបស់គាត់បានអត់ ?

ខ៖ បាន! បងទី ១ឈ្មោះ ឡេង ហុន ទី២ឈ្មោះ ហេង ... ហេង ចាន់ធី ទី ... ទី៣ ហេង ចាន់នី ទី៤ ហេង ចាន់នឿន នឹងទី៥ ហេង ណែម ហ្នឹង ។

ក៖ អ! អញ្ចឹងបងកូនពៅហ៎បង ?

ខ៖ ពៅ!

ក៖ អ័រ .... ចុះអ័រ ... ពួកគាត់សព្វថ្ងៃនេះពួកគាត់ទាំងអស់គ្នារស់នៅណាដែលបង ?

ខ៖ គាត់ស្លាប់អស់ មើល! ២នាក់ហើនៅ ៣នាក់បងប្អូន ។

កៈ បងអាចរៀបរាប់អ្នកដែលស្លាប់ គាត់ឈ្មោះអីដែលបង ?

ខៈ ឈ្មោះ ឡេង ហុន ។

កៈ ចាស!

ខៈ មួយទៀតឈ្មោះ ហេងចាន់នី ។

កៈ ចុះពួកគាត់ស្លាប់ដោយសារអីដែលបង ?

ខៈ ដោយសាររោគាពាធហ្នឹងណា ! ជំងឺ ។

កៈ ចុះអ័រ ... នាក់ទាំង ៣ទៀតតើអ័រ ... ពួកគាត់រស់នៅណាដែលបង ?

ខៈ មួយទៀតនៅស្រុក ស្ទឹងត្រង់ ឃុំ .... នេះហានៅខាង ចំការលើ ហា! ហើ ២ ... ២ទៀតនៅហ្នឹង ឃុំរំចេក យើងហ្នឹង ស្រុកកំពុងសៀម ហ្នឹង ។

កៈ ចុះបងមានចងចាំសាច់រឿងអី ខ្លះជាមួយពួកគាត់អត់ ?

ខៈ ចងចាំហ្នឹងអាមិច ?

កៈ ឧទាហរណ៍ថាមានអនុស្សាវរយ៍អីជាមួយ ពួកគាត់កាលនៅ ... នៅរស់នៅជុំគ្នាអញ្ជឹងហាណា ?

ខៈ កាលនៅជុំគ្នាពីចប់ អាពត
ហ្នឹងវាពិបាកនៅជុំគ្នាដល់ពេលបែកគ្នាទៅគេមានគ្រួសាររៀងៗខ្លួនទៅ ។

កៈ អញ្ជឹងហ៎ ?

ខៈ ចាស!

កៈ ចុះកាលនៅតូចៗមានធ្លាប់ធ្វើអីៗជាមួយគ្នាអត់ ? ទៅដើរលេងជាមួយគ្នា ឬក៏រកស៊ីអីជាមួយគ្នាហាដែលមានអត់ ?

ខៈ នៅតូចៗកាលនៅជុំគ្នាបែកគ្នាកាលជំនាន់ អាពត មានដែលនៅជុំឯណា ។ ដឹងក្តីឡើងបងៗទៅធ្វើ ដូចថាធ្វើចល័តអស់អញ្ជឹងទៅគាត់ទើបអាយុជាង ១០ឆ្នាំរួចឯងនៅក្មេងជាងគេមានអីគេអោយ រែកអាចម៍គោ ហីអាយុ ៧ឆ្នាំ ។

កៈ ចុះរែករួចអត់ចុះ ?

ខ៖ រែករួចមិនរួចចេះតែទៅហា! ចេះតែប្រឹងហាចេះតាទេសតាទាសទៅ
៧ឆ្នាំបើគេអោយរែកហីចេះតែរែកទៅ អាចម៍គោបើមិនប្រឹងខ្លាចគេវៃ ។

ក៖ ហ្ហ! បើយើងអត់ធ្វើគេវៃហ៎ ?

ខ៖ ហ្នឹងហី! វៃជំនាន់ អាពត ។

ក៖ អ៊ំរ ... ចុះបងប្អូនបងទាំងអស់គ្នាហ្នឹង តើគាត់ប្រកបមុខរបរអីខ្លះដែលទៅបង ?

ខ៖ គាត់ធ្វើស្រែ ចំការហ្នឹង! ស្រែចំការ ប៉ុនបងទី ៥ហ្នឹងឈឺសសៃប្រសាទអត់ដឹងអីផងហ្នឹង ។

ក៖ អ! ចុះឥឡូវ ... ឥឡូវគាត់ជានីបង ?

ខ៖ អត់! អត់ជាទេមើលទៅ បែបម៉ាជីវិតហីជំងឺហ្នឹង។

ក៖ ចុះ ... ចុះពីណាគេអ្នករាប់រងគាត់ទៅអញ្ចឹង ?

ខ៖ ខ្ញុំអ្នករាប់រងទាំងអស់ ឈឺ ២០ឆ្នាំជាងហីនៅហ្នឹង ។

ក៖ ចុះអ៊ំរ .... គាត់មានកូនអត់បង ?

ខ៖ កូន ២ ប៉ុន្តែគេមានគ្រួសារគេបែកមួយ នៅមួយទៀតមិនទាន់មានគ្រួសារ ។

ក៖ ហ៊ឹម! ចុះគាត់អត់មើលម្តាយរបស់គាត់ហេ ?

ខ៖ មើលហើយ ប៉ិនមិនជានៅតែអញ្ចឹងចេះតែទ្រាំទៅធ្វើមិច ?

ក៖ អញ្ចឹងបងចិញ្ចឹមគាត់ម៉ាជីវិតទៅ ?

ខ៖ ចិញ្ចឹមម៉ាជីវិត មិនដឹងធ្វើមិចបើអត់ជាមានតែម៉ាជីវិតអញ្ចឹងទៅ ពិបាករហូត ។

ក៖ បានបុណ្យច្រើនបង ចុះចំពោះឪពុកម្តាយរបស់បងវិញ តើពួកគាត់មានឈ្មោះអីដែលបង ?

ខ៖ ឈ្មោះ ឡេង ហោង មួយទៀតអ៊ំរ ... ម្តាយញ៉ុមឈ្មោះ វន សាត ប៉ុន្តែគាត់អនិច្ចកម្មយូហើយ ។

ក៖ អញ្ចឹង? ចុះឪពុករបស់បងអត់ទាន់អនិច្ចកម្មទេ ?

ខ៖ អនិច្ចកម្មទាំងអស់ហើយ ទាំងយាយទាំងតាហ្នឹង ។

ក៖ អ! ចុះបងចងចាំអ៊ំរ ... ថ្ងៃ ខែ ឆ្នាំ កំណើតរបស់គាត់អត់ ?

ខ៖ កុងដូចជាឆ្នាំ ១ពាន់ អឹម ... ៩២០មាណទេនៀក! ដូចភ្លេចដែល ។

ក៖ ២០?

ខ៖ ២០ជាងព្រោះឥឡូវ បើសិនជាគិតមកឥឡូវវា ៩០ ... ៩០ឆ្នាំជាង ហោ! ជិត១០០ហី ១០០ហី! ១០០ហី! ហ្នឹងហី! ហើយយាយបើគិតមកឥឡូវប្រហែលជា ៩០ហី ។

ក៖ ចាស!

ខ៖ គាត់ខូច ។

ក៖ ចុះបងដឹងពីកន្លែងកំណើតរបស់គាត់អត់ ?

ខ៖ គាត់នៅ ... នៅស្រុកហ្នឹងដែលកុង យាយនៅខាង ឃុំហាន់ជ័យ ។

ក៖ បងដឹង ភូមិ ឃុំ គាត់ហោ? ឈ្មោះ ភូមិ ឃុំ ស្រុក អីដែល ?

ខ៖ ឃុំហាន់ជ័យ ហ្នឹងហា! ស្រុកកំពុងសៀម ហ្នឹងយាយ បើកុងនៅឃុំ រំចេក ហ្នឹង ។

ក៖ ចាស!

ខ៖ ភូមិ ឈើទាលស្រុតលើ ឃុំ រំចេក ហ្នឹង ។

ក៖ ចុះអ័រ ... កាលឪពុកបងនៅរស់ តើគាត់ប្រកបមុខរបរអីគេបងដើម្បីចិញ្ចឹមជីវិតហា ?

ខ៖ គាត់ពីដើមមកគាត់រកត្រី ធ្វើប្រាំងហ្នឹងដល់ពេលគាត់ចាស់ទៅគាត់រកស៊ី កាត់សក់ ផងបោះត្បាល់កិន អីអញ្ចឹងទៅ ។

ក៖ ហ្ហ! ច្រើនមេះ!

ខ៖ អើ! ចាស់ហើយអត់ធ្វើអី ។

ក៖ អញ្ចឹងគាត់មានហី បើគាត់រកស៊ីច្រើនយ៉ាងហ្នឹង ។

ខ៖ មានអីគ្រាន់តែម៉ាគ្រប់គ្រាន់ហ្នឹង ។

ក៖ ចុះអត្តចរិករបស់គាត់ តើគាត់ជាមនុស្សបែបណាដែល ?

ខ៖ គាត់មានអីគាត់ តាំងពីក្មេងមកគាត់ស្លូតបូតគាត់ប្រកបរបរ កសិកម្ម ហ្នឹងគាត់មានទៅនេះអី ។

កៈ ចុះអ៊ំរ ... អ្នកម្ដាយរបស់បងវិញ តើគាត់រកស៊ីអីដើម្បីចិញ្ចឹមជីវិត ?

ខៈ គាត់ពីដើមមកគាត់ដាំ ម្ទូ លក់ម្ទូហ្នឹងហើមានតាអញ្ចឹងស្រុកយើងហ្នឹង ។

កៈ គាត់អត់មានមុខរបរអីផ្សេងដូចកុងទេ ?

ខៈ អត់ទេ! អត់មានទេ ។

កៈ តើគាត់ជាមនុស្សបែបណាដែល ?

ខៈ គាត់ជាមនុស្សឧស្សាហ៍ណាស់យាយហ្នឹង ដាំជី ដាំខ្ទឹម លក់គ្មានឈប់ទេរែកទឹកទល់អាយុ ៧០ ។

កៈ អូ!

ខៈ បានឈប់ រែកលែងរួចបានឈប់ ។

កៈ ចុះអត់មានពីណាគេជួយគាត់ហេ ?

ខៈ មានដែល ប៉ុនគ្រាន់ថាយើងនៅក្មេងអញ្ចឹងជួយគាត់ខ្លះទៅរៀនខ្លះទៅ មកវិញជួយគាត់ខ្លះទៅ ។

កៈ ចុះបងមានចងចាំសាច់រឿងអីជាមួយ នឹងឪពុកម្ដាយរបស់បងអត់ ?

ខៈ ចាំ! ចាំដូចថាគាត់ប្រឹងដាំ ជី ខ្ទឹម លក់បានបន្ដិចបន្តួចហ្នឹងសំរាប់យើងរៀនអញ្ចឹងហា ។

កៈ ចាស!

ខៈ ហ្នឹងហើ! ដល់ពេលគាត់ចាស់ទៅទំរាំថាបានយើងចិញ្ចឹមវិញគាត់ចាស់មែនទែន ងងូក់ហើយ ។

កៈ ចុះបងមានបានសងគុណគាត់អត់ ?

ខៈ បានសងគុណ ដូចថាគាត់ចាស់រស់នៅជាមួយយើងហ្នឹង ឈឺជាអីគាត់ជរាទៅនៅលើយើងហ្នឹង លើកដាក់ទល់តែគាត់ផុតជីវិតទាំងអស់ទាំងយាយទាំងកុង ។ អឹម! មានពីណាមានតាយើងហ្នឹងអ្នកថែរក្សាគាត់ ។

កៈ ចុះអ៊ំរ ... ពួកគាត់មានបានប្រាប់បងអំពីការលំបាក ឬក៏ការសប្បាយចិត្តនៅក្នុងដំណើរជីវិតរបស់គាត់អត់បង ?

ខ៖ គាត់ថាគាត់ពិបាក ប៉ុន្តែដូចថាម៉ាជំនាន់ទៅមួយជំនាន់គាត់លំបាក ហ្នឹងហី! រត់កប៉ាលហោះទៅនាំកូនរត់ចូល ត្រង់សេទៅ អាណារត់ទាន់មិនទាន់គេងាប់ទៅយើងរស់ទៅ អញ្ចឹងវាពិបាកហាម៉ាជំនាន់ណុង ។ ទំរាំមកបានស្រួលបន្តិចជួបជំនាន់ អាពត ទៀតរត់ទៅនៅស្រុកគេ រត់រែកអីវ៉ាន់រកេតរកាកទំរាំមកដល់ស្រុក មកដល់វិញគេយកអីៗអស់លើងនៅសល់តែសំបកផ្ទះគេកាច់ដុតជិតអស់ទៀតហី ហ៊ុយ! វេទនាហា!

ក៖ អញ្ចឹងមានន័យថា ពេលដែលបងរត់ចោលស្រុកហើយដល់ពេលមកវិញមករកផ្ទះខ្លួនឯងដដែល ?

ខ៖ មករកផ្ទះខ្លួនឯងដដែល ប៉ុន្តែមកដល់អស់ហើយជញ្ជាំងអីគេកាច់ដុតជិតអស់ហី ។

ក៖ ហាក! មិចគេកាច់ដុតវិញ ?

ខ៖ អើ! បើគេថាទឹកលិចអត់មានអីដុត គេមិនកាច់ដុតរួចអាផ្ទះហ្នឹងវល្លិស្អីៗ ននោង អីឡើងដំបូលលែងចង់ឃើញផ្ទះអស់ហើយ ។

ក៖ អញ្ចឹង ....

ខ៖ គ្រាន់បានតែឥវ៉ាន់បន្តិចបន្តួច តាម៉ា ... ម្នាក់ម៉ារែកហ្នឹងមានស្អីៗទេមានតែកន្ទេល ក្អើយ មានចាន ឆ្នាំង អីតែប៉ុនហ្នឹង ។

ក៖ អញ្ចឹងមានន័យថាបងឆ្លងកាត់ជំនាន់ ប៉ុលពត ដែលមែនហេបង ?

ខ៖ ជំនាន់ ប៉ុលពត ឆ្លងកាត់ដឹង! ដឹងច្បាស់ម៉ងព្រោះអាយុ ៧ឆ្នាំហីគេហៅទៅរែកអាចម៍គោ ។

ក៖ ហើរយេះពេលមាណឆ្នាំទៅទើបចប់ ?

ខ៖ ជំនាន់ អាពត ? គិតទៅដឹងក្តីឡើងជួបតាម៉ង! អើ! យើងទើប ៧ឆ្នាំហាណាដល់ពេលបានទំរាំបានចូលរៀនមកចប់ ៨ ចូល៨ឆ្នាំ ។

ក៖ ហ៊ឺម! អញ្ចឹងជំនាន់ ប៉ុលពត ហ្នឹងតែម៉ាឆ្នាំហេ ?

ខ៖ អត់ទេនិយាយដូចថា កាលណុង៧ឆ្នាំហា។

ក៖ ចាស!

ខ៖ អាយុ! អាយុហា! ជំនាន់ ប៉ុលពត មាណ ? ៣ឆ្នាំហី ? ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។

ក៖ ចាស! ចុះបងបានចូលរៀននៅអាយុមាណដែល ?

ខ៖ អាយុ ៨ឆ្នាំហីទំរាំចប់ អាពត ណុងបានរៀន ។

ក៖ អញ្ចឹង ? បងមានចងចាំអំពីជីដូនជីតារបស់បងអត់ ? ទាំងខាងម្ដាយទាំងខាងឪពុកហាអ័រ ... តើបងទាន់គាត់អត់ ?

ខ៖ អត់ទាន់ទេ! គ្រាន់តែលឺគាត់និយាយអញ្ចឹងហា ។

ក៖ ហ្នឹងហី! ចុះអ័រ ... ម្ដាយឪពុកបងបានរៀបរាប់ប្រាប់ពីជីដូនជីតាបងដល់បងអត់ ?

ខ៖ គាត់និយាយតា ជីដូនជីតាហ្នឹងនៅខាង មាន់ហើរ ប៉ុន្តែគាត់ ... ដូចថាគាត់ខូចទៅហ្នឹងតាំងពីបងប្រុសញុំអាយុបាន ៨ឆ្នាំប៉ុនមកយើងក្មេងក្រោយនេះអត់ទាន់ទេ អត់ទាន់ថាដឹងអាមិចខ្លះហេ ។

ក៖ អញ្ចឹងមានន័យថាគាត់ស្លាប់យូហើយមែនអត់បង ?

ខ៖ យូហី!

ក៖ ចុះបងអ័រ .... បងអាចចាំថ្ងៃ ខែ ឆ្នាំកំណើតគាត់ ឬក៏គាត់កើតថ្ងៃណា ? ខែណា ? ឆ្នាំណា ? អីអត់បងចាំហេ ?

ខ៖ កុងតួតយាយតួតណោះហ៎ ?

ក៖ ចាស!

ខ៖ អត់ដឹងម៉ងហ្នឹងហា ព្រោះយូហើយ ។

ក៖ អ័រ .... មាក់ប៉ាបងអត់ដែលនិយាយប្រាប់ទេណ៎ ?

ខ៖ អត់ដែលហេ ។

ក៖ ចំពោះក្រុមគ្រួសារបងរស់នៅក្នុងខេត្ត កំពុងចាម ហ្នឹងយូនៅបង ?

ខ៖ កំណើតដូចថាតាំងពីដូនតាហ្នឹងមកហា ។

ក៖ ចង់ ១០០ឆ្នាំហីចឹង ?

ខ៖ ១០០ឆ្នាំជាងហើ ។

ក៖ ចុះបងមានសាច់ញ្ញាតិរស់នៅក្រៅប្រទេសអត់បង ?

ខ៖ អត់មានទេ!

ក៖ អត់មានទេណ៎ ?

ខ៖ ចាស!

ក៖ អ៎រ .... បងមានគ្រួសារហើយនៅបង ?

ខ៖ មានហើយ!

ក៖ អ៎រ ... គ្រួសារបងឈ្មោះអីគេ ?

ខ៖ ឈ្មោះ ច្រិច ជា ។

ក៖ គាត់មាន ... គាត់កើតនៅក្នុងឆ្នាំណាដែល ?

ខ៖ ឆ្នាំ ១៩៧០ដូចគ្នា ។

ក៖ ហាក! អញ្ចឹងអាយុស្មើរគ្នាមែនបង ?

ខ៖ ស្មើរគ្នា ។

ក៖ ហៅបង ហៅប្អូនអញ្ចឹង ?

ខ៖ ហៅធម្មតា .... ស្រករគ្នា ។

ក៖ ចុះគាត់ .... ចុះគាត់អ៎រ ... ប្រកបមុខរបរអីដែលបង ?

ខ៖ គាត់ធ្វើប្រាំង ធ្វើចំការដូចតាគេដូចតាឯងកសិកហ្នឹង ។

ក៖ ចាស! ចុះទីកន្លែងកំណើតរបស់គាត់ គាត់កើតនៅណា ?

ខ៖ គាត់នៅខាងឃុំ ហាន់ជ័យ ភូមិមាន់ហើរ ។

ក៖ ភូមិមាន់ហើរ ឃុំហាន់ជ័យ ?

ខ៖ ហ្នឹងហើ! ឃុំហាន់ជ័យ ស្រុកកំពុងសៀម ខេត្តកំពុងចាម យើងហ្នឹង ។

កៈ ចាស! ចុះបងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែលបង ?

ខៈ អាពាហ៍ពិពាហ៍! កាលណុងការនៅឆ្នាំ ១៩៩០ ។

កៈ ១៩៩០ ?

ខៈ ហ្នឹងហើ!

កៈ នៅណាបង ?

ខៈ នៅភូមិ ឈើទាលស្រុតលើ យើងហ្នឹង ។

កៈ អ! ចុះអាពាហ៍ពិពាហ៍ហ្នឹងបងរៀបចំឡើងដោយខ្លួនឯង ឬក៏ឪពុកម្ដាយជាអ្នករៀបចំអោយ ?

ខៈ ឪពុកម្ដាយ ។

កៈ ឪពុកម្ដាយណំបង ? ចុះអ័រ ... សុំសួរបន្តិចអ័រ .... ពេលដែលបង ...
ពេលដែលបងជួបគ្នាហ្នឹងជាស្នេហ៍គ្រាដំបូងមែនបង ?

ខៈ ហ្នឹងហើ! តែមួយហ្នឹង ។

កៈ តែមួយហ្នឹងអត់ដែលមានចិត្តទៅពីណាក្រៅពីគាត់ទេណំ ?

ខៈ អត់! អត់សោះ! ម៉ែទុកឪពុកដាក់ ។

កៈ ចុះពេលំណុងបានជួបគ្នាអត់ ? បានជួបមុខគ្នាអីអត់ ? ឃើញគ្នាអីអញ្ចឹងហា ?

ខៈ ដែលឃើញម្ដងម៉ាកាលដែលប៉ុន អត់ចំណាំទេបើឃើញច្បាស់ថ្ងៃការហ្នឹង ។

កៈ អញ្ចឹងមានន័យថា ឃើញច្បាស់ .... ស្គាល់ច្បាស់ថ្ងៃការម៉ង ?

ខៈ ហ្នឹងហើ!

កៈ ចុះបើអត់ស្អាត់អីធ្វើមិចទៅដល់ពេលថ្ងៃការយកអត់ ?

ខៈ តាមម៉ែឪ! ម៉ែអោយទៅអាមិច .... កាលជំនាន់ណុងតាមម៉ែឪអត់ដឹងទៅជួបគ្នាមិច
បើប្រពៃណីយើងអញ្ចឹង ។

កៈ ចុះអ័រ ... បងរៀបការនៅអាយុមាណដែល ?

ខ៖ អាយុអ័រ ... ២០គត់ ។

ក៖ ២០គត់ដូចជាមិនក្មេងមាណាទេ ល្មម ។

ខ៖ ២០គត់!

ក៖ មិចបានចាស់ៗជំនាន់ណុងអោយតែរៀបការអត់ដែលជួបមុខគ្នាអញ្ចឹង
ដល់តែថ្ងៃការបានស្គាល់គ្នាម៉ង ?

ខ៖ និយាយទៅដូចថា ក្មេងស្រីម៉ាជំនាន់ណុងមិនសូវអោយដើរចេញទៅណាទេណា ។
ថារៀនអោយប្រាកដជារៀន បើយើងចេញទៅណេះទៅណោះខ្លាចគេនិយាយថាយើងហ្នឹង
លួចស្រលាញ់កូនគេអីអញ្ចឹង! មិនហានសូម្បីតែកូនគេមានកូនកំលោះហ្នឹងអត់ហានទៅផ្ទះគេទេ
ខ្លាចគេថា ស្រលាញ់កូនគេដល់អញ្ចឹងអត់ហានដើរទៅណា ។

ក៖ អ! មានអញ្ចឹងទៀត ?

ខ៖ ជំនាន់មុនអញ្ចឹង! មែនដូចជំនាន់ឥឡូវហេ ស្គាល់គ្នាតាមចិត្ត ។

ក៖ ហើធ្វើមិចបានគេឃើញយើង គេមកដណ្ដឹងយើងទៅបើអត់ដែលជួបគ្នា
អត់ដែលចេញទៅក្រៅផងធ្វើមិចគេដឹងថាផ្ទះហ្នឹងមានកូនក្រមុំ ?

ខ៖ ដឹងតាមរយៈចាស់ៗ។

ក៖ ហ្វ! ចុះពេលណុងបងបានថ្លៃជំនួនមាណាដែលបង ?

ខ៖ ថ្លៃជំនូនកាលណុង ប៉ុន្មានទេ ? ដូចជា ៣ ... ៣៥០០ ហ្នឹងច្រើនហាណា ។

ក៖ ៣៥០០ ?

ខ៖ ៣៥០០ លុយយើងហ្នឹង! ខ្មែរយើងហ្នឹង ។

ក៖ អ!

ខ៖ កាលណុង! ជំនាន់ណុងចង់តែ ៧០រៀល ៦០រៀល ៥០រៀល អីហ្នឹង ។

ក៖ អ! បានច្រើនមែនណុងហា ។

ខ៖ បានច្រើន (សើច) ។

កៈ ចុះបងនិយាយភាសារខ្មែរ នឹងអានបានល្អអត់បង ?

ខៈ បានល្អ!

កៈ ចាស! ចុះភាសារដទៃអីបងចេះហេ ? ភាសារផ្សេងៗ ?

ខៈ អត់សូវចេះមាណទេ ព្រោះកាលណុងរៀនបានតិចហា អង់គ្លេស រៀនបានតិចតួចបំផុតម៉ង ។

កៈ អ! កាលណុងបងបានរៀនភាសារ អង់គ្លេសដែលណ៎ ?

ខៈ រៀន បារាំង ទេកាលជំនាន់ណុងហ៎ ។

កៈ រៀនបារាំង! អាចចាំអីម៉ាម៉ាត់ ២ម៉ាត់អីអត់បង ?

ខៈ ចាំអ័រ ... អក្សរឡាតាំងហ្នឹងហី ក៏ .... ?

កៈ បើ .... ឧទាហរណ៍ថាអានហា អាចអានបានអត់ ? ដូចឧទាហរណ៍ថាជួបជាមួយនឹងភាសារបារាំងអីអញ្ចឹង លើសៀវភៅអីអញ្ចឹងហាអាចអានដាច់អីអត់ ?

ខៈ អានដាច់ខ្លះដែល ប៉ុនគ្រាន់ថាអានតា ពាក្យស្រាលៗដូចជាអ័រ .... សត្វអីអញ្ចឹងយើង ... ដូចជាឆ្កែ យើងហៅអាឡឺស៊ាងអញ្ចឹងទៅហ្នឹងហី ។

កៈ ចាស!

ខៈ ហ្នឹងហី! Baby អីអញ្ចឹងទៅដឹងតែកូនង៉ែតហី កាលណុងអត់រៀនទេ អង់គ្លេស រៀន បារាំង ។

កៈ ចាស!

ខៈ រៀនបាន ១ខែ ២ខែ ប៉ុនដូចថាយូទៅដូចភ្លេចអស់ហើយ ចង់ភ្លេចអស់ហើយ ។

កៈ ហ្នឹងហីយូហី ។

ខៈ យូហី!

កៈ ចុះបងកាលបងរៀនណុង រៀនបានថ្នាក់ទីប៉ុន្មានបង ?

ខៈ រៀនកាលជំនាន់ណុង យើងប្រលងឌីសប្លូម .... ប្រលងឌីសប្លូម!

កៈ ប្រលងឌីសប្លូម ។

ខ៖ ហ្នឹងហី!

ក៖ ថ្នាក់ទី ៩ ។

ខ៖ បើឥឡូវគេថាថ្នាក់ទី ៩ ប៉ុនកាលណុងតាថ្នាក់ទី ៧ហេ ។

ក៖ ថ្នាក់ទី ៧ ?

ខ៖ ទី៧!

ក៖ អ! ចុះរៀននៅសាលាណាដែលបង ?

ខ៖ សាលាយើងនៅ មាន់ហើរ ហ្នឹងសាលា ....

ក៖ អនុវិទ្យាល័យ ហាន់ជ័យ ។

ខ៖ ហាន់ជ័យ! ហាន់ជ័យ នៅក្នុងវត្ត មាន់ហើរនេះ ។

ក៖ ហ្នឹងហី! វិទ្យាល័យ ហាន់ជ័យ ។

ខ៖ ហាន់ជ័យ ។

ក៖ ចាស! អ័រ .... ចុះទីតាំងសាលាហ្នឹងនៅណាដែលបង ?

ខ៖ នៅក្នុងវត្តម៉ង វត្ត ... សាលាវត្តមាន់ហើរ ហ្នឹងម៉ង ។ នៅក្នុងវត្តកាលណុងមិនទាន់មានសាលា ឈិនលាន ណា!

ក៖ ចាស!

ខ៖ មិនទាន់មានទេ ។

ក៖ ហ្នឹងហី! អ័រ ... ចុះបងមានមិត្តភ័ក្តស្និទ្ធស្នាលដែលបងធ្លាប់រៀនជាមួយ ហើយធំធាត់មកជាមួយគ្នាអត់ ?

ខ៖ មាន! ប៉ុនគ្រាន់ថានៅវាឆ្ងាយហាណា ។

ក៖ ចាស!

ខ៖ ភាគច្រើនកាលណុងច្រើនពួកខាង កោះ ។

កៈ ចាស! អ័រ ... តើអាចលើក ... រៀបរាប់ឈ្មោះគាត់បន្តិចបានអត់ ?

ខៈ និយាយអញ្ចឹងមើល ... មិត្តភ័ក្តដែលស្និទ្ធស្នាលនៅ ហាន់ជ័យ ប៉ុន្តែដូចថាបែកគ្នាអស់ហើយណា។

កៈ ចាស!

ខៈ ដូច ចាន់ណា ស្រីអូន តុលា ម្នាក់ហ្នឹងអាយុ ១៥ឆ្នាំប៉ុន្តែដល់ពេលនេះឈឺងាប់ ។

កៈ អូ! មិចចឹង ?

ខៈ ពួកម៉ាក់ស្និទ្ធមែនទែន! មួយទៀត ៣៧ នៅខាង កោះជ្រូក ។

កៈ ចាស!

ខៈ ខាង កោះជ្រូក ហ្នឹងគ្នា ២ ៣នាក់ហំដូច លៃហ៊ា អីហ្នឹងប៉ុន្តែតឡូវគេនៅ ... លក់ឥវ៉ាន់នៅឯផ្សារពុងចាម ប៉ុនគេស្គាល់ដែលដូចថាយើងទៅលេងអីអញ្ចឹងហា ។

កៈ ចាស!

ខៈ អាហ្នឹងសុទ្ធតែមិត្តភ័ក្តស្និទ្ធស្នាលដែលអ្នកមកនៅនឹង ។

កៈ ចាស!

ខៈ អ្នកដែលមកស្នាក់រៀននៅផ្ទះយាយ យាង អីហ្នឹងស្និទ្ធស្នាលហា ប៉ុន្តែដល់ពេលនេះទៅសុទ្ធ ... និយាយ ... ភាគច្រើនដូចថានៅក្នុងស្រុកនឹងរៀនម្នាក់ ២នាក់ប៉ុនគេមកពីឆ្ងាយអីអញ្ចឹង ។

កៈ ចាស!

ខៈ បានស្គាល់ភាគតិចណាស់ រៀនជំនាន់ណុងរៀន ... មិនសូវមានទេថ្នាក់ ត្រឹមថ្នាក់ទី ៥ ទី៤ អីហ្នឹងគេឈប់អស់ហើយព្រោះយើងទី ៦ ទី៧ ហ្នឹងប្រឹងដើម្បីប្រលង ឌីសប្លូម ។

កៈ ចាស!

ខៈ ប្រលងហើយជាប់ ជាប់អត់មានលុយរៀនយើងអាយុអត់ទាន់ដល់ហា ។

កៈ ចាស!

ខៈ រួចណាមួយគេថាយើងកូនស្រី យើងទៅរៀននៅខេត្តអីអញ្ចឹងទៅវាអត់ល្អអីអញ្ចឹងហា ។

កៈ គេអត់អោយរៀន ?

ខៈ ដល់អញ្ចឹងអត់បានទៅរៀនសោះកុំអីបានធ្វើ គ្រូបាត់ហី ដោយសារអី ? ដោយសារជីវៈភាព។

កៈ ចាស!

ខៈ ទី២ អត់មាន ដូចថាអត់មានកងជិះទៅរៀនអីអញ្ចឹងហា ។

កៈ អត់មានសំភារៈ ។

ខៈ ព្រោះយើងខ្លួនជាស្រីទៀត ។

កៈ ហ្នឹងហី!

ខៈ រួចជាប់តែឯងកាលជំនាន់ណុង អញ្ចឹងបានថាកំសត់ហា ។

កៈ ចុះបងអាចអ័រ .... រៀបរាប់ទីកន្លែងដែលមិត្តភ័ក្ករបស់បងរស់នៅបានអត់ ?
មិត្តភ័ក្តដែលបងថាស្និទ្ធស្នាលមិញហ្នឹង តើពួកគាត់រស់នៅណាខ្លះ ?

ខៈ នៅខាង ហាន់ជ័យ កោះ នឹងខាង ភូមិថ្មី ខ្លះ គៀនជ្រៃ យើងហ្នឹង ។

កៈ ចុះពួកគាត់ប្រកបមុខរបរអីគេឥឡូវហ្នឹង ?

ខៈ ខ្លះគេធ្វើការខ្លះទៅ ខ្លះគេធ្វើដូចជា ... កសិករដូចយើងអញ្ចឹងទៅអ្នកធ្វើស្រែ ចំការ ។

កៈ ចុះបងនៅទាក់ទងជាមួយពួកគាត់តាហីបង ?

ខៈ ស្គាល់តាពេលជួបគ្នាម្តងម្កាលអី ជួបគ្នារាប់អានគ្នាធម្មតា ។

កៈ ចុះបងមានចងចាំសាច់រឿងអីខ្លះជាមួយពួកគាត់អត់ ?
ពេលដែលនៅរៀនអីអញ្ចឹងហាមានចាំអនុស្សាវរីយ៍ល្អៗអីជាមួយគាត់អត់ ?

ខៈ ចងចាំដូចថាពេលបែកគ្នាអញ្ចឹង យើងនឹកហា!

កៈ ចាស!

ខៈ នឹកគ្នាហាអោយតាបាន ជួបគ្នាម្តងៗនិយាយលេង ... និយាយលេងពីក្រុមគ្រួសារអី
រកស៊ីមុខរបរអី កូនប៉ុន្មានអីអញ្ចឹងហាហ្នឹងហី ។

កៈ ចុះកាលនៅរៀនហ្នឹងមានអនុស្សាវរីយ៍អីជាមួយពួកគាត់ខ្លះ ?

ខ៖ និយាយទៅមិនសូវបានដើរលេងណាផង រៀននៅតែនឹងសាលាហ្នឹង អត់សូវបានដើរលេងដូចក្មេងឥឡូវហេ ។ ណាមួយវាអត់មានកង់ជិះយើងទៅតែដើរហ្នឹងរៀនហ៎ ។

ក៖ ដើរអញ្ចឹងឧទាហរណ៍គេចូលម៉ោង ៧ ទៅម៉ោងមាណ ?

ខ៖ ដើរពីព្រលឹមទៅ ទៅដល់ម៉ាតិចទៅគេរៀនចូលរៀនម៉ោង ៦ ម៉ោង ៦កន្លះអីអញ្ចឹងទៅ ។

ក៖ ម៉ោង ៦កន្លះចូលរៀន ?

ខ៖ ម៉ោង ៧ ប៉ុន្តែយើងដើរទៅទំរាំដល់សាលាពីត្រឹមហ្នឹងទៅ មាន់ហើរ ដើររហូតអត់មានកង់ជិះទេ ។

ក៖ ហ្នឹងហី! ចុះបងធ្លាប់ធ្វើការនៅស្រែអីអត់ ? ធ្វើស្រែធ្វើអីអត់ ?

ខ៖ ធ្វើតា! និយាយទៅធ្វើរាល់ឆ្នាំ ។

ក៖ ចុះបើក្រៅពីស្រែបងមានជំនាញអីផ្សេងទៀតអត់ ?

ខ៖ មុនធ្វើបន្លែ ចំការ ប៉ុនដល់ពេលឥឡូវអត់ធ្វើអីទេធ្វើតែស្រែម៉ាមុខ ។

ក៖ មិចចឹង ? មិចបានធ្វើតែស្រែម៉ាមុខ ?

ខ៖ ធ្វើបន្លែធ្វើអីទៅវាអត់ចំនេញ ។

ក៖ ហូ!

ខ៖ ធ្វើទៅចេះតែខាតជំពាក់គេសងគេមិនរួចឈប់ទៅ ។

ក៖ ហាត់ហីជំពាក់គេទៀត ?

ខ៖ ហាត់ហីជំពាក់គេទៀត! ធ្វើតែស្រូវម៉ាមុខទៅ ។

ក៖ ចុះស្រូវហ្នឹងចំនេញហេបង ?

ខ៖ ចំនេញដែលឆ្នាំហ្នឹង បានគ្រែលដែល ។

ក៖ អ! បានមាណដែលបង ?

ខ៖ បាន ៥០ ៦០បេ ៦០បេជាង ។

កៈ ចុះជីវិតបងតាំងពីក្មេងមកដល់ឥឡូវមានការផ្លាស់ប្ដូរអត់ ?

ខៈ ផ្លាស់បន្ដិចដែល កាលម៉ាវក់មុនកូនច្រើនយើងនៅក្មេងពិបាកណាស់កូនតូច ចាស! ដល់ពេលឥឡូវកូនណុងចេញទៅអាចផ្ដល់អោយបានខ្លះហើយ អាចចិញ្ចឹមក្រុមគ្រួសារបានដូចថារាងធូរជាងមុនហា ។

កៈ ចាស! ចុះមានម្ហូបអីដែលបងចូលចិត្តពិសារជាងគេ ?

ខៈ ចូលចិត្តជាងគេមានតា ម្ហូបញុំ នឹង ទឹកគ្រឿង ម្ហូបខ្មែរ ។

កៈ ចុះបងចេះធ្វើអត់បង ?

ខៈ ចេះធ្វើតា! និយាយទៅម្ហូបខ្មែរចេះទាំងអស់ ។

កៈ ចុះប្ដីបងចូលចិត្តអត់បង ?

ខៈ ចូលចិត្តតា ។

កៈ អ! ចឹងត្រូវគ្នាហីចឹង ។

ខៈ ត្រូវគ្នា! (សើច)

កៈ ចុះបើល្បែងប្រជាប្រិយវិញបងចូលចិត្ត ចូលចិត្តលេងអីគេជាងគេ ?

ខៈ មិនសូវដែលដើរទៅលេង ប៉ុនចូលចិត្តមើលគេរាំ ។ ចាស! ហ្ន! អត់ចេះទេ អត់ចេះទេល្បែងក្រៅពីល្បែងប្រជាប្រយិអត់ចេះ បានត្រឹមទៅមើល ទៅមើល ។

កៈ ចុះមិចអត់ចូលលេងនឹងគេអញ្ចឹង ?

ខៈ លេងណាយើងចាស់ហើយ ។

កៈ ចុះបើចំពោះចំរៀងវិញបងចូលចិត្តអត់ ?

ខៈ ចូលចិត្តណាស់ ។

កៈ បងចេះច្រៀងអីអត់ ?

ខៈ អត់ចេះច្រៀងទេ ប៉ុនចូលចិត្តស្ដាប់ ។

កៈ តើមាននណារគេនៅក្នុងគ្រួសារបងហា ចេះលេងឧបករណ៍ភ្លេងអីហេ ?

ខ៖ អត់មានទេ!

ក៖ អត់មានទេណ៎ ?

ខ៖ ចាស!

ក៖ ចុះផ្ទះបងតាំងពីតូចរហូតមកដល់ឥឡូវមានលក្ខណះប្រែប្រួល ឬក៏ផ្លាស់ប្តូរអីអត់ ?

ខ៖ ផ្ទះហ្នឹងតាំងពីម្តាយមករហូតទល់ ... គិតទៅយើងអាយុ ៤០ មើល! ៤៧ ហើយគិតទៅមែនតិចទេណាប្រហែលឡាបាក់ ៦០ឆ្នាំជាងហី ។

ក៖ អត់មានការប្រែប្រួលអីទេ ?

ខ៖ អត់ទេ! អត់ទាន់ ... អត់មានដូចថាយើងមិនទាន់បានធ្វើថ្មីអីទេ ។

ក៖ ចាស!

ខ៖ នៅផ្ទះចាស់ពីម្តាយមក ។

ក៖ អញ្ចឹងផ្ទះហ្នឹង ផ្ទះអ៊័រ .... តំណពីម្តាយរបស់បងមកណ៎ ?

ខ៖ ហ្នឹងហី!

ក៖ ចុះបងមានជំនាញអីដែលតវេន បន្តវេនពីម្តាយឪពុកអីអត់បង ?

ខ៖ តវេន! យើងមានអីមានតាធ្វើស្រែ ធ្វើចំការណុងបើគាត់មានអីមានស្រុកយើង និយាយទៅដូចថាស្រុកភូមិយើងវាអញ្ចឹងទាំងអស់គ្នា យើងធ្វើតែស្រែហើយនឹង បន្លែ ហីមានចំការអីបន្តិចបន្តួចហ្នឹង ។

ក៖ អ! អ៊័រលឺកាលខាងដើម លឺថាបងម្តាយរបស់បងគាត់ដាំម្លូ បងអត់មានដាំម្លូអីទៀតទេឥឡូវ ?

ខ៖ ឥឡូវ ម្លូ ណាបើគេធ្វើផ្លូវអស់ហើយដី ម្លូ ។

ក៖ គេយកដីធ្វើផ្លូវអស់ហើយ ។

ខ៖ ធ្វើផ្លូវអស់ហើយមានអី ។

ក៖ អត់មានដីកន្លែងណាដាំ ម្លូ អីគេីតទៀតទេហ៎ ?

ខ៖ អត់មាន! អស់ហើយ ។

កៈ ចុះចំពោះកាលលំបាកនៅក្នុងជីវិតរបស់បងវិញ
តើអ្វីដែលបងគិតថាជាការលំបាកខ្លាំងបំផុតនៅក្នុងជីវិតរបស់បង ?

ខៈ និយាយរឿងលំបាកណុង វាខ្លាំងបំផុតសឹងថាម៉ាស្រុកដូចលំបាកជាងគេត្រង់ថា ចិញ្ចឹមម្ដាយ
ចិញ្ចឹមឪពុក ចិញ្ចឹមបង ចិញ្ចឹមក្មួយ ក្មួយកំព្រាដល់ ២ ៣សំបុកដល់ពេលម៉ែឪគេទៅរកស៊ី
ចេញទៅរកស៊ីនៅលើយើងទាំងអស់ ។ ចិញ្ចឹមទំរាំបានគេចេញម្ដង១ៗ ជាង ១០នាក់ហ៎!
ម៉ាក្រុមគ្រួសារហ្នឹង ។

កៈ ចាស!

ខៈ បាយឆ្នាំលេងដាក់ ៧កំប៉ុងលើកអត់ចង់រួចហេ ។

កៈ ម៉ាបេមាណខែ ? អ! មាណថ្ងៃទៅ ?

ខៈ ម៉ាបេបានជូនណា ១៣ថ្ងៃ ១៥ថ្ងៃ ម៉ាបេ ។

កៈ ហើគ្រួសារបងអត់ថាអីទេហ៎ ? ដល់ពេលចិញ្ចឹមតាគេអញ្ចឹងរហូត ?

ខៈ គាត់អត់ចេះមាត់! និយាយទៅគាត់អត់ចេះមាត់ទេ គាត់ដឹងតែធ្វើការ ។

កៈ អ! គាត់ល្អហើចឹងហ៎ ។

ខៈ ចាស!

កៈ ចុះបងអ័រ ... ដោះស្រាយការលំបាកហ្នឹងដោយរបៀបណាទៅ ?

ខៈ និយាយទៅយើងចេះតែធ្វើស្រូវទៅ រួចពីស្រូវទៅ បន្លែ
ទៅចេះតែទៅប្រដាក់ប្រដូសគេទៅទំរាំរួចពីមួយឆ្នាំ ទៅមួយឆ្នាំបានរស់ទាំងវេទនា ហ្វ! ពិបាកហា!
ទំរាំបានកូនធំៗអញ្ចឹងទៅបានវាជួយ ។ ចាស! ជួយអញ្ចឹងទៅ
ឥឡូវបានវាចេញរកការងារធ្វើខ្លះទៅរាងធូរបន្តិចទៅ ។

កៈ ចុះអ្នកដែលបងជួយទាំងប៉ុនម៉ាមាណណុងមាន ... គាត់
ឥឡូវហ្នឹងគាត់មានជួយបងវិញអត់ឥឡូវហ្នឹង ?

ខៈ ជួយរាល់ថ្ងៃហ្នឹងបានកូន ជួយ ។

កៈ អ! អ្នកដែលបងជួយឧទាហរណ៍ថាអ័រ ... មានទាំងក្មួយ មានទាំងបង មានទាំងប្អូនអីហ្នឹងហា តើគាត់មានបានជួយបងវិញអត់ឥឡូវ ?

ខៈ ជួយតា! ជួយច្រើនហាច្រើនលើសលុប ដូចកាលយើងជួយវាណុងបានត្រឹមបាយម្ហូបអីអញ្ចឹងហា ហីហ្នឹងផ្គត់ផ្គង់ការសិក្សាហ្នឹងខ្លះ ប៉ុន្តែឥឡូវដល់ពេលវាជួយវិញដូចច្រើនលើសលុបជាងយើងជួយក្មេងពីមុនហា។

កៈ ចាស! អញ្ចឹងបានគេថាអំពើរល្អតបមកវិញអំពើរល្អវិញ អញ្ចឹងធ្វើតាល្អទៅបានល្អមកវិញហី ។

ខៈ អាហ្នឹងអញ្ចឹងហី ។

កៈ ហ្នឹងហី!

ខៈ ធ្វើល្អបានល្អ ។

កៈ តែសម័យឥឡូវធ្វើល្អបានអាក្រក់ ។

ខៈ អត់ជឿរហោ។

កៈ ហ្នឹងហី! មកពីបងឯងធ្វើចំជាមួយមនុស្សល្អដែល តែបើធ្វើចំមនុស្សអាក្រក់ធ្វើល្អបានអាក្រក់ហី ។

ខៈ ហ៊ឹម! មកពីបុណ្យយើងដែល ។

កៈ ហ្នឹងហី! ចុះចំពោះអ័រ ... ការចងចាំដែលល្អបំផុតនៅក្នុងជីវិតរបស់បង តើអីគេដែល ?

ខៈ ចងចាំខ្លាំងដូចថាដែលរឿងដែលល្អហា ហ្នឹងហី! ឃើញកូនហ្នឹងប្រលងជាប់ ហ្នឹងហី! ជាប់បាក់ឌុប ហើយបានរៀន រៀនហើយប្រលងជាប់ កូរ៉េ ទៀតបាន ២នាក់ជាប់ថាអរសឹងថាហោះដូចជើងហ្នឹងផុតដីអស់ហើយអរ ។

កៈ ចាស!

ខៈ អរដល់ថ្នាក់ដេកអត់លក់សឹង ... សឹងចង់យំហាំមែនហា ។

កៈ ចុះម្ដាយណាមិនអរឃើញកូនបានល្អ ។

ខៈ ហ្នឹងហី! ឃើញកូនហ្នឹងដូចថាដោយគន្លងធម៌យើងប៉ងអីប្រាថ្នាអីយើងបានដូចបំណងអញ្ចឹងហា ។

កៈ ចាស!

ខៈ ហ្នឹងហើ!

កៈ ចុះបងមានអ័រ ... បុត្រាបុត្រីមាណនាក់ដែល ?

ខៈ ៦នាក់ ។

កៈ អ័រ ... ពួកគាត់មានឈ្មោះអីដែល?

ខៈ ទី១ឈ្មោះ ជា ស្រីនាថ ទី២ ជា ចិន ទី៣ ជា ម៉េងជាវ ទី៤ ជា ស្រីណា ទី៥ ជា ស្រីណុច ទី៦ ជា សុជាតិ ។

កៈ អ! បងមាន បងមានកូន ជា សុជាតិ មួយទៀតណាំបង ? ចុះអ័រ ... បងថាកូន កូនណាខ្លះដែលទៅ កូរ៉េ ហាំ ?

ខៈ ក្មួយ! ក្មួយអាលែងម្ដាយឈឺសសៃប្រសាទហ្នឹង ។

កៈ អ!

ខៈ នៅជាមួយហ្នឹងកូន២យក ... កូនបងយកប្ដីហើយប៉ុន្ដែនៅអាប្អូនពៅហ្នឹងទៅ កូរ៉េ បានជិតម៉ាអាណត្តិហើ ប៉ុនកូនខ្ញុំកូនទី២ ហ្នឹង ជា ចិន ហ្នឹងទៅបាន ១ឆ្នាំកន្លះទៅ កូរ៉េ ដែលប៉ុនរៀនអត់ទាន់បានចប់ឆ្នាំទី ៤ ផងហ្នឹងនៅ ១ឆ្នាំទៀត ។

កៈ អ! គាត់រៀនសកលហាំបង ?

ខៈ រៀនសកល ។

កៈ គាត់រៀនជំនាញអីដែល ?

ខៈ ខាង IT ។

កៈ អ! អត់អីទេចាំមកវិញចាំត ។

ខៈ នៅខ្វះតែ ៣ខែទៀតតា ប៉ុន្ដែវាអត់បានមកប្រលង ។

កៈ ចុះអ័រ ... កាលបងនៅតូចហាកាលបងនៅរៀនហា តើបងមានបំណងប្រាថ្នាចង់ធ្វើអីគេពេលដែលបងកំពុងតែរៀនអញ្ចឹង ?

ខ៖ និយាយរឿងបំណង ប៉ងថាចង់បានធ្វើគ្រូ
ប៉ុន្តែអត់ដូចបំណងសោះអញ្ចឹងបានអោយកូនខំរៀនព្រោះយើងប៉ងអត់បាន ។

ក៖ ចាស!

ខ៖ ដល់ប៉ងអត់បាន នឹកឃើញថាយើងមើលទៅដូចគ្មានវាសនាអោយកូនខំប្រឹងរៀន
ប៉ុន្តែឥឡូវវាបានរៀនសកលហើដល់ទៅ ២ហើណា ។

ក៖ ចាស! អ័រ ... មួយណាខ្លះដែលបានរៀនសកល ?

ខ៖ សកល ចិន នឹង ម៉េងជាវ រៀនចូលឆ្នាំទី២ ហើនៅសាលា ភូមិន្ទយើងហ្នឹង ។ ហ្នឹងហើដល់
ស្រីណា រៀនដល់ថ្នាក់ទី ១១ ហើ ។

ក៖ តើបងមានបំណងចង់អោយគាត់រៀន សកលដែលអត់ ?

ខ៖ ចង់ទាំងអស់ ទាំង៦នាក់ ៥នាក់ហ្នឹង ។

ក៖ ចាស!

ខ៖ ព្រោះយើងអត់បានដូចបំណងហើ អោយកូនប្រឹង ។ ហ្នឹងហើ! សុខចិត្តក្រចុះ
ក្រម៉ារយះពេលសិនចុះក្រែងលោថ្ងៃក្រោយយើងវាបានធូរជាងហ្នឹង ។

ក៖ ចាស! ចុះអ័រ ... ក្នុងនាមបងជាម្ដាយបងចង់អប់រំកូន ឬក៏ប្រៀមប្រដៅ
ឬក៏ផ្ដាំផ្ញើរកូនថាមិចដើម្បីអោយអ័រ ... កូនចៅបងជំនាន់ក្រោយគាត់អ័រ ....
ស្ដាប់កន្លងធម៍របស់បងអីអញ្ចឹងហាណា ? តើបងមានពាក្យពាជន៍អីផ្ដាំផ្ញើរពួកគាត់អត់ ?

ខ៖ យើងគ្រាន់ថាប្រដៅកូនថា អោយដើរតែផ្លូវល្អ យើងនឹងជួបអ្នកដែលល្អនឹង ... ដូចថាយើង ...
ម៉ែឪយើងក្រពិបាកអញ្ចឹងហើយកុំអោយកូនហ្នឹង ពិបាកដូចយើងទៀតហ្នឹងហើតែប៉ុនហ្នឹង
កុំអោយគេថាតពូជហាណា ។

ក៖ ចាស!

ខ៖ ថា ហា! ក្រហា! ពូជវាហ្នឹងក្រហាពូជយើងកុំអោយគេថា តហា!

ក៖ ចាស!

ខ៖ ប្រឹងប្រែងដើម្បីកុំអោយវា គេហៅតពូជវាខ្ពសើជាងម៉ែឪហ្នឹងទៀត ។

កះ ហ្នឹងហើ! ដូចពាក្យស្លោកគេនិយាយ ( កើតមកក្រវាមិនមែនជាកំហុសហេ ប៉ុន្តែបើស្លាប់ហើយនៅតែក្រទៀតហ្នឹងបានជាកំហុស ) ។

ខះ ហ្នឹងហើ! ល្អពាក្យស្លោកហ្នឹង ។

កះ ហ្នឹងហើ!
ហ្នឹងអញ្ចឹងអគុណាដល់បងច្រើនដែលផ្ដល់ឧកាលអោយញ៉ុមបានសម្ភាសន៍បងនៅថ្ងៃនេះណាបង អគុណាច្រើនបង ។